01026564

E314/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 09 / 2014
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Sann Rada

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** |

## សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើម សំណុំរឿង ០០២/០២

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

01026565

E314/5

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើមួយ ("សំណើ") សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពន្យារកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូលសម្រេចរួចរាល់លើបណ្តឹងសារទុក្ខនានាលើសាលក្រម សំណុំរឿង ០០២/០១ ព្រមទាំងបណ្តឹងសាទុក្ខដទៃទៀតពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១។ បើមិនដូច្នោះទេ មេធាវីការពារក្តី ខៀវ សំផន ទាមទារឱ្យដកសិទ្ធិពីប្រធានអង្គជំនុំជម្រះសាលាដំបូង ចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LARVERGE ចៅក្រម យូរ ឧត្តរា និងចៅក្រម Claudia FENZ ចេញពីការជំនុំជម្រះក្តីបន្ថែមទៀតណាមួយក្នុងសំណុំរឿង ០០២[1]។ ការិយាល័យសហព្រះរាជអាជ្ញាបានដាក់ចម្លើយតបនៅថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤ ("ចម្លើយតប")[2]។

## ២. សារណា

២. មេធាវីការពារក្តីបានលើកឡើងថា កាលៈទេសៈថ្មីពីរតម្រូវឱ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញសាជាថ្មីលើបញ្ហានេះ[3]។ មេធាវីការពារក្តីលើកឡើងថា កាលៈទេសៈថ្មីទីមួយគឺសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ដែលបានតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកសំណុំរឿង ០០២ បន្ថែម និងវិសាលភាពសំណុំរឿង ០០២/០២ ។ សេចក្តីសម្រេចនេះបញ្ជាក់ពី "ហានិភ័យនៃការយល់ឃើញជាន់គ្នាអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលក្នុងការជំនុំជម្រះបន្តបន្ទាប់"[4]។ កាលៈទេសៈថ្មីទី២ គឺការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ កាលពីថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤។ បើយោងតាមក្រុមមេធាវីការពារក្តី សាលក្រមនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងតាមពិតបានរក

[1] សំណើរបស់លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំផ្អាកកិច្ចដំណើរការនីតិវិធី ឬប្តឹងជំទាស់ចៅក្រម ឯកសារ E314/3 ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤។

[3] សំណើ កថាខណ្ឌ ៧។

[4] សំណើ កថាខណ្ឌ ៩។

ឃើញសំអាងហេតុស្ដីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទពាក់ព័ន្ធនឹងបទចោទនានា ដែលនឹងត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២[5]។

៣. ពាក់ព័ន្ធនឹងខ្លឹមសារនៃបញ្ហានេះ មេធាវីការពារក្ដី ខៀវ សំផន ស្នើថា អង្គជំនុំជម្រះសាលាដំបូង បានបំពេញកិច្ចលើសពីវិសាលភាពនៃការជំនុំជម្រះក្ដី ដែលមានសំអាងហេតុក្នុងសាលក្រមសំណុំរឿង ០០២/០១ ទាក់ទងនឹងបញ្ហាដែលត្រូវបានចោទប្រកាន់ក្នុងវិសាលភាពសំណុំរឿង ០០២/០២[6] ។ ដោយផ្អែកលើសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូល មេធាវីការពារក្ដីបានលើកឡើងថា សំអាងហេតុទាំងអស់នេះ ដែលកំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលគឺត្រួតគ្នារវាងសំណុំរឿងទាំងពីរ និងនាំឱ្យខូចប្រយោជន៍ដល់ជនជាប់ចោទ[7]។ ហេតុដូច្នេះហើយ មេធាវីការពារក្ដីបានលើកឡើងថា កាលៈទេសៈនេះតម្រូវឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធី រហូតទាល់តែអង្គជំនុំជម្រះតុលាការកំពូលសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ រួចរាល់ជាមុនសិន[8]។

៤. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការផ្អាកកិច្ចដំណើរការនីតិវិធីមិនចាំបាច់នោះទេនៅក្នុងកាលៈទេសៈទាំងនេះ[9]។ សហព្រះរាជអាជ្ញាបានលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលខ្លួនឯង ដែលបានប្រមើលឃើញថា ការចាប់ផ្ដើមសំណុំរឿង ០០២/០២ ត្រូវធ្វើ "ឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន" ហើយទោះក្នុងកាលៈទេសៈណាក៏ដោយ ក៏ការចាប់ផ្ដើមនេះត្រូវធ្វើឡើងមុនពេលប្រកាសសាលដីកាស្ថាពរលើបណ្ដឹងសារទុក្ខក្នុងសំណុំរឿង ០០២/០១ ដែរ[10] ។

---

[5] សំណើ កថាខណ្ឌ ១០ ដល់ ៤៣, ៤៥, ៤៧, ៥៣, ៥៤។

[6] សំណើ កថាខណ្ឌ ២៣ ដល់ ៣៥។

[7] សំណើ កថាខណ្ឌ ៣៦ ៣៩ ដល់ ៤២ និង ៥២។ *សូមមើលផងដែរ* សំណើ កថាខណ្ឌ ៩ *ដែលយោងទៅ* សេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ E301/9/1/1/3 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤") កថាខណ្ឌ ៨៥។

[8] សំណើ កថាខណ្ឌ ១០, ៤៦, ៤៧, ៥៤។

[9] ចម្លើយតប កថាខណ្ឌ ២ ដល់ ២៤។

[10] ចម្លើយតប កថាខណ្ឌ ៦។

01026567

E314/5

## ៣. សំអាងហេតុ

៥. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា អង្គជំនុំជម្រះធ្លាប់បានពិចារណា និងបដិសេធម្តងហើយលើសំណើស្រដៀងគ្នានេះពីមេធាវីការពារក្តី ខៀវ សំផន សុំឱ្យពន្យារកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២[11]។ វិធានផ្ទៃក្នុងមិនមានចែងពីការពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទេ។ ប៉ុន្តែ អង្គជំនុំជម្រះអាចពិចារណាលើបញ្ហាណាមួយជាថ្មី ប្រសិនបើមានការចាំបាច់ដោយសារមានកាលៈទេសៈថ្មីកើតឡើង[12]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទាំងសាលក្រមសំណុំរឿង ០០២/០១ ព្រមទាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ត្រូវបានចេញរួចរាល់ហើយ ចាប់តាំងពីមានសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ។ អង្គជំនុំជម្រះយល់ឃើញថា នេះគឺមិនមែនជាកាលៈទេសៈថ្មី និងជាករណីលើកលែងដែលត្រូវឱ្យពិចារណាសាជាថ្មីទៅលើបញ្ហានេះនោះទេ។

៦. នៅក្នុងសំណើសុំរបស់ខ្លួន មេធាវីការពារក្តីទាមទារឱ្យផ្អាកកិច្ចដំណើរការនីតិវិធី ឬបើមិនដូច្នោះទេ សុំដកសិទ្ធិពីចៅក្រមមួយចំនួននៅក្នុងក្រុមប្រឹក្សាជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូង។ ទឡ្ហីករណ៍របស់មេធាវីការពារក្តីចំពោះការស្នើសុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធីនេះផ្អែកលើការអះអាងថា សំអាងហេតុមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង បានធ្វើឡើងហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយសំអាងហេតុនេះប្រាកដជាជះឥទ្ធិពលដល់ការវាយតម្លៃពីពិរុទ្ធភាពរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ ជាមិនខាន។ ហេតុដូច្នេះ មេធាវីការពារក្តីស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពន្យារពេលការចាប់ផ្តើមសំណុំរឿង ០០២/០២ រហូតទាល់តែសាលក្រមសំណុំរឿង០០២/០១ ចូលជាស្ថាពរ។

៧. សំណើសុំផ្អាកកិច្ចដំណើរការនីតិវិធីត្រូវតែថ្លឹងថ្លែងជាមួយកាតព្វកិច្ចរបស់តុលាការនេះ ក្រោមមាត្រា ៣៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដើម្បីធានាការជម្រះក្តីដោយយុត្តិធម៌ និងឆាប់

---

[11] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលដីកាស្ថាពរលើសំណុំរឿង ០០២/០១ ឯកសារ E301/5/5/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤") ទំព័រ ៧។

[12] សេចក្តីសម្រេចលើសំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញចំពោះសេចក្តីសម្រេចរបស់ខ្លួនដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងសំណើសុំបន្ថែម ឯកសារ E238/11/1 ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៧។ សេចក្តីសម្រេចស្ថាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E312 ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ៣៩។

របស់។ ក្នុងន័យនេះ តុលាការត្រូវតែពិចារណាលើផលប្រយោជន៍របស់ភាគីទាំងអស់[13]។ អង្គជំនុំជម្រះរម្លឹកថា ទាំងក្រុមមេធាវីការពារក្ដី នួន ជា និង សហព្រះរាជអាជ្ញា សុទ្ធតែបានជំរុញឱ្យអង្គជំនុំជម្រះសាលាដំបូងចាប់ផ្ដើមដំណើរការជំនុំជម្រះសំណុំរឿង ០០២/០២ ឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន[14]។ ដូចគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូលក៏បានជំរុញជាច្រើនលើកច្រើនសាឱ្យអង្គជំនុំជម្រះសាលាដំបូងចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ឱ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបានផងដែរ[15]។ ថ្មីៗនេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ពីផលប្រយោជន៍ដ៏ចាំបាច់បំផុតក្នុងការធានាឱ្យបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ តាមរយៈសេចក្ដីសម្រេចមួយក្នុងពេលដែលជនជាប់ចោទទាំងពីរនៅមានជីវិតនៅឡើយ យ៉ាងហោចណាស់លើបទចោទនានាដែលនៅសេសសល់ដែលរួមនឹងបទចោទនានាក្នុងសំណុំរឿង ០០២/០១ ដែលបង្កើតបានភាពជាតំណាងសមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល[16]។ កន្លងមក អង្គជំនុំជម្រះបានបញ្ជាក់រួចមកហើយថា គេអាចប៉ាន់ស្មានដោយសមហេតុផលបានថា អង្គជំនុំជម្រះតុលាការកំពូលប្រាកដជានឹងចេញសាលដីកាលើសំណុំរឿង ០០២/០១ នៅមុនពេលការជំនុំជម្រះក្ដីណាមួយក្នុងសំណុំរឿង០០២/០២ ត្រូវបានបញ្ចប់[17]។ ដូចនេះ ភាគីទាំងអស់នឹងមានឱកាសនៅពេលនោះដាក់សារណាទៅអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងសំអាងហេតុណាមួយ ដែលអង្គជំនុំជម្រះតុលាការកំពូលសម្រេច ដែលមានការពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២។ ការធ្វើបែបនេះមិនមានអ្វីដែលធ្វើឱ្យប៉ះពាល់ដោយអយុត្តិធម៌ដល់ជនជាប់ចោទនោះទេ ដោយសារភាគីដទៃទៀតក្នុងសំណុំរឿង ០០២/០២ នឹងស្ថិតក្នុងស្ថានភាពស្រដៀងគ្នានេះដែរ។

៨. អង្គជំនុំជម្រះយល់ឃើញថា វិធានផ្ទៃក្នុងមានចែងតែពីកាលៈទេសៈមួយចំនួនតូចប៉ុណ្ណោះ ដែលចាំបាច់ត្រូវផ្អាកកិច្ចដំណើរការនីតិវិធី។ កាលៈទេសៈដែលមេធាវីលើកឡើងនៅពេលនេះមិនស្ថិតនៅក្នុងកាលៈទេសៈដែលមានចែងក្នុងវិធានផ្ទៃក្នុងទេ។ អនុលោមតាមវិធាន ៣៤(៥) នៃវិធានផ្ទៃ

[13] *សូមមើល* សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

[14] ចម្លើយតប កថាខណ្ឌ ២៤, ប្រតិចារិកថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ ទំព័រ ៣៨ (ភាសាអង់គ្លេស) (**លោក កូប៉េ៖** សូមអរគុណលោកប្រធាន។ ក្រុមមេធាវីលោក នួន ជា - ការពារក្ដីលោក នួន ជា គឺថាត្រៀមខ្លួនជាស្រេចដើម្បីចូលរួមសវនាការឆ្នាំ ២០១៤ និង ២០១៥។ ហើយយើងជំរុញឱ្យអង្គជំនុំជម្រះឱ្យចាប់ផ្ដើមសវនាការឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន)។

[15] *សូមមើល* សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ១០។

[16] *សូមមើល* សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៥៥, ៦២, ៨៧។

[17] *សូមមើល* សេចក្ដីសម្រេចរបស់ អ.ជ.ស.ដ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤។

E314/5

ក្នុង សូម្បីតែសំណើសុំជាជម្រើសមួយទៀតរបស់មេធាវីការពារក្តី ដែលស្នើដកសិទ្ធិចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះមួយចំនួននោះ ក៏មិនតម្រូវឲ្យផ្អាកកិច្ចដំណើរការនីតិវិធីដែរ។

៩. ពាក់ព័ន្ធនឹងសំណើជាជម្រើសមួយទៀតរបស់មេធាវីការពារក្តី ស្នើសុំដកសិទ្ធិពីចៅក្រមមួយចំនួននោះ នេះជាបញ្ហាដែលចៅក្រមដែលត្រូវបានចាត់តាំងដោយគណៈកម្មការរដ្ឋបាលតុលាការត្រូវពិនិត្យ និងសម្រេចទៅលើបណ្តឹងជំទាស់ចៅក្រមទាំងនេះ[18]។

**តាមសម្អាងហេតុដូចបានរៀបរាប់ខាងលើនេះ អង្គជំនុំជម្រះសម្រេច÷**

**បដិសេធ** សំណើសុំពន្យារពេលកិច្ចដំណើរការនីតិវិធីរបស់ ខៀវ សំផន។

**បញ្ជូន** សំណើដែលជាជម្រើសមួយទៀតរបស់មេធាវីការពារក្តី ខៀវ សំផន ស្នើសុំដកសិទ្ធិចៅក្រមមួយចំនួនពីក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្ន ទៅឲ្យចៅក្រមដែលត្រូវបានតែងតាំងដោយគណៈកម្មការរដ្ឋបាលតុលាការដើម្បីពិនិត្យ និងសម្រេច។

ភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * CHAMBRE DE PREMIÈRE INSTANCE * E.C.C.C. * C.E.T.C.

**និល ណុន**

[18] អនុស្សរណៈអន្តរការិយាល័យរបស់គណៈកម្មការរដ្ឋបាលតុលាការ ឯកសារ E314/4 សេចក្តីសម្រេចរបស់គណៈកម្មការរដ្ឋបាលតុលាការទាក់ទងនឹងការចាត់តាំងសមាសភាពចៅក្រមដើម្បីពិនិត្យនិងវិនិច្ឆ័យលើបណ្តឹងជំទាស់ប្រឆាំងនឹងចៅក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៤។